**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៩
## ទីស្តីការគណៈរដ្ឋមន្ត្រី
## ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងកិច្ចប្រជុំនាពេលនេះ!**

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុសផុល ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ សមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ ដែលខ្ញុំសូមសង្ខេបជូនដូចតទៅ ៖

**ទី១ :** ការអនុម័តជាគោលការណ៍នូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រយៈពេល៦ខែចុងឆ្នាំ២០១៩។

**ទី២ :** ការអនុម័តជាគោលការណ៍នូវ ផែនការយុទ្ធសាស្ត្រទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៩-២០២៣។

**ទី៣ :** ការបន្តជំរុញឱ្យមានវឌ្ឍនភាព និងការបន្តការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។ និង

**ទី៤ :** ការអនុម័ត សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៩ សម្រាប់បន្តអនុវត្តក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្ពោះទៅសម្រេចបាននូវគោលដៅ៩៥-៩៥-៩៥ នាឆ្នាំ២០២៥។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

ទោះបីជាពេលវេលារបស់យើងមានពេលតែមួយព្រឹកក៏ពិតមែន តែដោយសារតែមានការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កា ដែលខ្ញុំសូមយកឱកាសនេះសម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុតជូនសមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែចុងឆ្នាំ ២០១៩ ទៅតាមក្រសួង ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ឯលទ្ធផលដែលយើងទទួលគឺអាចខុសៗគ្នាទៅតាមស្ថានភាពជាក់ស្តែងរបស់ស្ថាប័ននីមួយៗ។

២) សូមអបអរសាទរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងផែនការ និងក្រសួង ស្ថាបន័ពាក់ពន្ធ័ ដែលបានចូលរួមជំរុញឱ្យមានកិច្ចប្រជុំនានា ក្នុងការអនុវត្តឆ្លើយតបនឹង "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។ មកទល់ពេលនេះ យើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ។

៣) សូមលើកទឹកចិត្តក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបន្តជួយបង្កើន និងសម្របសម្រួលដល់ការប្រើប្រាស់ថវិកាជាតិ ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍។

៤) សូមលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ឱ្យបន្តជំរុញនិងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

៥) កង្វះខាតថវិកានៅតែជាបញ្ហាចម្បងមួយ រារាំងដល់ការអនុវត្តផែនការសកម្មភាពឱ្យបានពេញលេញទៅតាមការគ្រោងទុក ឬក៏លទ្ធភាពក្នុងការពង្រីកអត្រាគ្របដណ្តប់ទៅកាន់ក្រុមគោលដៅថ្មី ជាពិសេសក្រុមប្រឈម។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាព ឆ្នាំ២០២០ខាងមុខ។

**២) ជំរុញនិងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យក្នុងការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។**

៣) បន្តចូលរួមជា "**ចរន្តជាតិមួយ**" ក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

៤) ប្រឹងប្រែងអនុវត្តសេចក្តីសម្រេចចិត្តនៃសម័យប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៩ ដែលទើបបានទទួលការអនុម័តនាពេលនេះ។

៥) បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័នដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកាឆ្នាំ២០២១ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័នសាមីឱ្យបានព្រមៗគ្នា។

៦) បន្តជំរុញ និងលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និង រាជធានី ខេត្ត ក្នុងការផ្តល់របាយការណ៍ឱ្យបានទៀងទាត់មកអាជ្ញាធរជាតិប្រយុទ្ធនឹង

ជំងឺអេដស៍ ដើម្បីពង្រឹងការអនុវត្តគោលការណ៍បីមួយ ៖ ស្ថាប័នដឹកនាំសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រតែមួយ និងប្រព័ន្ធតាមដានត្រួតពិនិត្យតែមួយ។

៧) បន្តធ្វើការសិក្សានិងរកវិធីសាស្ត្រដែលមានលក្ខណៈឆ្នៃប្រឌិត ក្នុងការបន្តនូវការវិនិយោគថវិកាជាតិបន្ថែមទៀត ដើម្បីពន្លឿនការសម្រេចបានគោលដៅទៅតាមការគ្រោងទុក។

៨) បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់បន្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាទៅមុខទៀត រហូតសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ជាស្ថាពរ ជាពិសេសគ្រប់គ្រងឱ្យបានទាំងស្រុងក្រុមប្រឈម ដែលតម្រូវឱ្យមានកម្មវិធីឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ដូចដែលយើងបានធ្វើចំពោះ ក្រុមនារីបម្រើសេវាកម្សាន្តសប្បាយនៅតាមគ្រឹះស្ថាននានាផងដែរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ។ តាមរយៈការចូលរួមយ៉ាងសកម្ម ផ្តល់នូវគំនិតល្អៗ រួមជាមួយនឹងមតិដ៏ល្អ និងមានតម្លៃ នាំឱ្យយើងអសាចកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់នូវពុទ្ធពរទាំងឡាយទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ខ្ញុំសូមប្រកាសបិទ **“កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ ២០១៩”** ចាប់ពីពេលនេះតទៅ!

***សូមអរគុណ!***